គណៈកម្មាធិការរៀបចំ
Organizing Committee

# សេចក្តីប្រកាសព័ត៌មាន

## ប្រជាជនបានសួរថា "តើអ្នកណាធំជាង គណបក្ស ឬពលរដ្ឋ?"

**រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមិថុនា៖** អ្នកចូលរួមដែលជា តំណាងសហគមន៍ សង្គមស៊ីវិល និងគណបក្សនយោបាយ ប្រមាណជាង ៣៥០នាក់ បានជួបជុំគ្នា ដើម្បីស្តាប់តំណាងគណបក្សនយោបាយធំៗ អំពីគោលនយោបាយរបស់ខ្លួននៅក្នុងអំឡុងពេលឈានដល់ការបោះឆ្នោតជាតិនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។

"វាគឺជាគោលការណ៍គ្រឹះនៃសង្គមប្រជាធិបតេយ្យមួយ ដែលប្រជាពលរដ្ឋមានសិទ្ធិដឹងលឺនូវជំហរនៃគោលនយោបាយទាំងឡាយរបស់គណបក្ស។ ថ្ងៃនេះ ពលរដ្ឋកម្ពុជាបានបង្ហាញថា ពួកគេពិតជាចង់សួរដេញដោលពីគោលនយោបាយរបស់គណបក្សនីមួយៗ" លោក ឈិត សំអាត នាយកប្រតិបត្តិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាបានមានប្រសាសន៍។

ថ្ងៃនេះ គណបក្សសង្គ្រោះជាតិ (CNRP) និងគណបក្សហ្វ៊ុនស៊ិនប៉ិច បានចូលរួមក្នុងវេទិកាស្តីពីទស្សនៈនយោបាយ ហើយបានឆ្លើយសំណួរទាក់ទងនឹងបញ្ហាជាច្រើន។ វាគ្មិនតំណាងគណបក្ស ត្រូវបានស្នើឲ្យបង្ហាញពីគោលនយោបាយរបស់ខ្លួនក្រោមប្រធានបទសំខាន់ៗចំនួនបួនគឺ (១)**កំណែទម្រង់សេដ្ឋកិច្ច និងដីធ្លី** (២) **បរិស្ថាន ព្រៃឈើ និងបម្រែបម្រួលអាកាសធាតុ** (៣) **ការអភិវឌ្ឍសង្គម និងមនុស្ស និង** (៤) **នីតិរដ្ឋ អភិបាលកិច្ចល្អ និងការទទួលព័ត៌មាន។** គណបក្សប្រជាជនកម្ពុជា(CPP) បានបដិសេធមិនចូលរួម។

អ្នកចូលរួម និងគណៈកម្មការរៀបចំកម្មវិធី បានសម្តែងនូវការខកចិត្ត ដែលគណបក្សប្រជាជនមិនបានចូលរួមក្នុងវេទិកានេះ បើទោះជាមានការអញ្ជើញជាច្រើនដងក៏ដោយ។ យោងតាមគោលការណ៍ប្រជាធិបតេយ្យ គណបក្សនយោបាយទាំងអស់ ត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ លើគោល-នយោបាយរបស់ខ្លួន នៅមុនពេលបោះឆ្នោត។

អ្នកចូលរួម រួមមានតំណាងសហគមន៍មកពីទូទាំងប្រទេសកម្ពុជា។ ពួកគេ បានសម្តែងនូវកង្វល់ចំបងៗមួយចំនួន ដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងតម្លាភាព ព្រមទាំងការជម្លៀសចេញពីដីធ្លី។ ក្រៅពីនេះ មានការសម្តែងនូវការព្រួយបារម្ភ អំពីតម្លាភាពក្នុងការគ្រប់គ្រងចំណូលដែលនឹងរំពឹងទុកពីវិស័យឧស្សាហកម្មនីស្សារណកម្ម។

បញ្ហាដែលត្រូវបានសង្កត់ធ្ងន់ជាដដែលៗពីអ្នកចោទសួរ គឺតម្រូវការឲ្យមានការអនុវត្ត និងពង្រឹងច្បាប់ដីធ្លី និងបទប្បញ្ញត្តិដទៃទៀតដែលមានស្រាប់ឲ្យមានប្រសិទ្ធភាព។

គណបក្សនយោបាយទាំងពីរបានយល់ស្របទៅលើតម្រូវការឲ្យមានឯករាជ្យភាពនៃប្រព័ន្ធតុលាការកាន់តែខ្លាំង និងការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។

វេទិកានេះ គឺជាព្រឹត្តិការណ៍ដ៏ធំបំផុត របស់ក្រុមអង្គការសង្គមស៊ីវិល ដែលបានរៀបចំសម្រាប់អំឡុងពេលឈានដល់ការបោះឆ្នោតជាតិខាងមុខនេះ។ លោកស្រី ធីតា ឃឹះ ដែលជាសមាជិកមួយរូបនៃគណៈកម្មាធិការរៀបចំ និងជានាយិកាប្រតិបត្តិនៃអង្គការសីលការ ក៏បានមានប្រសាសន៍ដែរថា ព្រឹត្តិការណ៍នេះខុសប្លែកពីព្រឹត្តិការណ៍មុនៗ ដែលបានរៀបចំឡើងនៅក្នុងប្រវត្តិសាស្ត្ររបស់សហគមអង្គការមិនមែនរដ្ឋាភិបាល។ លោកស្រីបានបន្តទៀតថា "អង្គការសង្គមស៊ីវិល បានបង្ហាញនូវភាពជាម្ចាស់កាន់តែច្រើន ក្នុងដំណើរការផ្តល់ព័ត៌មានដល់ពលរដ្ឋ អំពីជម្រើសនៃការបោះឆ្នោត"។

###

**គណៈកម្មាធិការរៀបចំ**
**Organizing Committee**

វេទិកានេះ បានប្រមូលផ្តុំនូវអ្នកចូលរួមដែលជាតំណាងសហគមន៍ និងតំណាងសង្គមស៊ីវិល គណបក្សនយោបាយ ដៃគូអភិវឌ្ឍន៍ និងស្ថានទូត។ អ្នកចូលរួមបានសម្តែងនូវសេចក្តីសប្បាយរីករាយដែលមានឱកាសសួរសំណួរទៅកាន់តំណាងគណបក្សនយោបាយ។

"វេទិកានេះគឺល្អណាស់ ពីព្រោះបានផ្តល់ឱកាសឲ្យពួកយើងបានលើកឡើងនូវក្តីកង្វល់អំពីការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា" នេះជាប្រសាសន៍របស់លោកស្រី ទឹម សាកមុន្នី ដែលជាប្រជាពលរដ្ឋមកពីសហគម បុរីកីឡា។

ប៉ុន្តែគាត់ក៏បានបញ្ជាក់ផងដែរថា ពេលវេលាហាក់ដូចជាខ្លីបន្តិច ដែលធ្វើឲ្យគាត់មិនអាចសួរនូវសំណួរទាំងអស់ដែលគាត់មាន។

លោក ហួ ឆែងន់ ដែលជានិស្សិតមកពីខេត្តកំពង់ចាម បាននិយាយថា "វាមានសារៈសំខាន់ណាស់ចំពោះខ្ញុំដែលជានិស្សិតក្នុងការមានឱកាសពាំនាំនូវចម្ងល់សួរទៅអ្នកតំណាងគណបក្សទាំងអស់ ហើយនឹងចែករំលែកនូវព័ត៌មានដែលខ្ញុំទទួលបានទៅមិត្តភ័ក្ត្ររបស់ខ្ញុំ"។ "ខ្ញុំសូមសំណូមពរឲ្យ គណបក្សទាំងអស់ចូលរួមក្នុងព្រឹត្តិការណ៍នេះ ព្រោះវាជាឱកាសជួយឲ្យពួកគេបានលឺពីកង្វល់ និងបញ្ហារបស់ពលរដ្ឋខ្លួន ហើយយើងចង់ឲ្យគណបក្សនយោបាយផ្តល់នូវដំណោះស្រាយរបស់ខ្លួនចំពោះបញ្ហាទាំងនោះ"។

លោកស្រី មុំ សាគីន មកពីសហគមន៍ព្រៃឈើខេត្តក្រចេះ បាននិយាយថា "បញ្ហាទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ គឺជាក្តីកង្វល់ដ៏ធំបំផុតសម្រាប់ពួកយើង។ ថ្ងៃនេះ គឺជាឱកាសមួយសម្រាប់ខ្ញុំក្នុងការស្តាប់នូវចម្លើយទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើ ដែលយើងមិនដែលបានឃើញមាននៅក្នុងការពិភាក្សានានាតាមរយៈទូរទស្សន៍ក្នុងស្រុក។"

ប្រធានបទដ៏មានប្រជាប្រិយភាពមួយ ដែលអ្នកចូលរួមភាគច្រើនបានលើកឡើងទៅកាន់គណបក្សនយោបាយគឺ "**ប្រសិនបើអ្នកជាប់ឆ្នោត តើអ្នកណាធំជាង គណបក្ស ឬពលរដ្ឋ**?"

**ចប់**

**ព្រឹត្តិការណ៍នាពេលខាងមុខរួមមាន៖** វេទិកាបោះឆ្នោតដែលផ្តោតទៅលើបញ្ហារបស់ស្ត្រី នាថ្ងៃទី១២ ខែមិថុនា នៅទីក្រុងភ្នំពេញ - បញ្ហាយុវជន ថ្ងៃទី១៥ ខែមិថុនា និងបញ្ហាដីធ្លី និងបរិស្ថាននាថ្ងៃទី១៩ ខែមិថុនា នៅខេត្តមណ្ឌលគីរី ព្រមទាំងពិធីចុះហត្ថលេខាលើការប្តេជ្ញាចិត្ត និងឆន្ទៈរបស់គណបក្សនយោបាយក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនាថ្ងៃទី១២ ខែមិថុនា។

**សមាជិកគណៈកម្មាធិការរៀបចំ រួមមាន៖** វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា - គណៈ កម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) - ខុមហ្វ្រែល - គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) - អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GADC) - គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP) - មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) - អង្គការសីលការ (SILAKA)- អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូ ក្នុងសកម្មភាព (DPA) - សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) - វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) - អង្គការតម្លាភាពអន្តរជាតិ (TI) - មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCiM) និង អង្គការទស្សនៈពិភពលោកកម្ពុជា (WVC)។ វេទិកានយោបាយនេះ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱកាសប្រជាពលរដ្ឋ បានស្តាប់ពីគោលនយោបាយនៃគណបក្សនយោបាយចំបងៗដែលចូលរួមក្នុងការបោះឆ្នោត។

**ទំនាក់ទំនង៖**
**លោក ឈិត សំអាត** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ០១២ ៩២៨៥៨៥
**លោក គល់ បញ្ញា** នាយកប្រតិបត្តិ អង្គការខុមហ្វ្រែល ០១២ ៩៤២ ០១៧
**លោកស្រី ធីតា ឃឹះ** នាយិកាប្រតិបត្តិ អង្គការសីលការ ០១២ ៨៣៨ ៤៦៤

###